# មជ្ឈមណ្ឌលឯកសារកម្ពុជា

## របាយការណ៍
## ស្តីពីទីតាំងពិឃាតនៅស្រុកបាទី ខេត្តតាកែវ
## ពីថ្ងៃទី២៩-៣១ ខែកក្កដា ឆ្នាំ២០០០

ដោយ ផេង ពង្សរ៉ាស៊ី

ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០០ ក្រុមស្រាវជ្រាវនៃមជ្ឈមណ្ឌលឯកសារកម្ពុជារួមមានផាត កុសល, អ៊ុច សំអឿន, សុខ វណ្ណៈ និង ផេង ពង្សរ៉ាស៊ីបានធ្វើដំណើរទៅកាន់ស្រុកបាទី ខេត្តតាកែវតាមផ្លូវជាតិលេខ២ ។ គោលបំណងគឺដើម្បីស្រាវជ្រាវទៅលើទីតាំងមន្ទីរសន្តិសុខនិងទីតាំងសម្លាប់នៅវត្តសូរភីហៅកកោះ និងវត្តទ្រព្យគរក្នុងស្រុកបាទី ។ ស្រុកបាទីមានព្រំប្រទល់ខាងត្បូង និង ខាងកើតជាប់នឹងខេត្តកណ្តាល, ខាងជើងជាប់នឹងស្រុកព្រៃកប្បាស និងខាងលិចជាប់នឹងខេត្តកំពង់ស្ពឺ ។ ប្រជាជនច្រើនប្រកបរបរធ្វើស្រែនិងឡើងត្នោត ។ ក្នុងរបបខ្មែរក្រហម១៩៧៥-៧៩ ស្រុកបាទីជាស្រុក លេខ៥៦, តំបន់១៣, ភូមិភាគនិរតី ។

### មន្ទីរសន្តិសុខ និង ទីតាំងសម្លាប់នៅវត្តកកោះ

វត្តនេះស្ថិតនៅក្នុងភូមិកណ្តឹងធំ ឃុំកណ្តឹង ស្រុកបាទី ។ ការធ្វើទារុណកម្ម និង សម្លាប់មនុស្សនៅទីតាំងវត្តកកោះត្រូវបានប្រព្រឹត្តទៅតាំងពីចុងឆ្នាំ១៩៧៣ (តំបន់នេះគឺជាតំបន់រំដោះតាំងពីឆ្នាំ ១៩៧៣ មកម្ល៉េះ) និង បន្តរហូតមកដល់ចុងឆ្នាំ១៩៧៨ ពេលកងទ័ពវៀតណាមវាយរុញច្រានពីទិសខាងកើតវត្តនេះមក ។ ការធ្វើទារុណកម្មក្នុងអំឡុងពេលនោះនៅមានកំរិតខុសៗគ្នាពីមួយឆ្នាំទៅមួយឆ្នាំ ។ សំដីរបស់លោកតា សូរ ញ៉ី អាយុ៦៩ឆ្នាំ មានទីលំនៅបច្ចុប្បន្ននៅភូមិកណ្តឹងធំ ឃុំកណ្តឹង ស្រុកបាទីដែលបានជាប់ឃុំឃាំងក្នុងមន្ទីរសន្តិសុខនៅវត្តកកោះកាលពីចុងឆ្នាំ១៩៧៣និយាយថា នៅពេលដែលគាត់ត្រូវបានចាប់ខ្លួនពីបទជេរទៅលើបក្សពួកខ្មែរក្រហម ហើយត្រូវនាំខ្លួនមកកាន់ព្រះវិហារវត្តកកោះ(មន្ទីរសន្តិសុខ) ភ្លាម ស្រាប់តែបានឃើញមនុស្សជាប់ខ្នោះចំនួនពីរខ្សែ ហើយក្នុងមួយខ្សែៗមានអ្នកទោសចំនួនពី២០ទៅ៣០នាក់ ។ ប្រជាជនដែលរស់នៅក្បែរៗព្រះវិហារវត្តនោះមួយចំនួនត្រូវបានជម្លៀសចេញទៅកាន់តំបន់ឆ្ងាយៗគឺមិនឲ្យមានអ្នកភូមិអ្នកស្រុកនៅក្បែរទីនោះទេ ។ អ្នកទោសខ្លះត្រូវស្លាប់ដោយអត់អាហារ ខ្លះស្លាប់

ដោយការធ្វើទារុណកម្មរបស់ខ្មែរក្រហម ។ ម្យ៉ាងទៀតអ្នកទោសដែលត្រូវយកទៅសម្លាប់សុទ្ធតែបានពុពាក្យមួយម៉ាត់ចុងក្រោយថា“**អង្គការឲ្យឡើងទៅតំបន់**” ។

លោកតាក៏បានប្រាប់បន្តថាអ្នកណាក៏ដោយ(អ្នកជាប់ទោស)ឲ្យតែពុពាក្យខាងលើនេះគឺគ្មាននរណាម្នាក់មានជីវិតរស់នៅតទៅទៀតឡើយ ។ នៅថ្ងៃមួយនាដើមឆ្នាំ១៩៧៨ លោកតាបានពុពាក្យនេះតាមរយៈកងឈ្លបម្នាក់ដែលមិនស្គាល់ឈ្មោះ ដែលបានទទួលបញ្ជាពីសមមិត្ត **ពុត**ជាប្រធានគុកនៅវត្តកកោះឲ្យមកប្រាប់គាត់ ។ លោកតាព្រលឹងចុងសក់! ព្រោះគាត់នឹកស្មានថាត្រូវបានយកទៅសម្លាប់ដោយគ្មានកំហុសនៅទីវត្តកកោះនេះហើយ ។ ទីបំផុតលោកតាត្រូវបានដោះលែងចេញពីគុកវិញ ។ លោកតារំលឹកថា លោកតាបានពាំនាំនូវពាក្យផ្តាំផ្ញើរបស់ប្រធានគុកឈ្មោះសមមិត្ត ពុត មិនឲ្យប្រាប់គេឯងថាមានការសម្លាប់មនុស្ស ហូបមិនឆ្អែត មានការធ្វើទារុណកម្ម នៅក្នុងមន្ទីរវត្តកកោះនេះឡើយ ។ ក្រោយពីនោះមកការចេញចូលអ្នកទោសនៅតែបន្តជាដរាបគ្មានថ្ងៃលោះ ។ លោកតាត្រូវបានបញ្ជូនទៅឆ្ងាយ ហើយពុំបានដឹងថាព្រឹត្តិការណ៍បន្តមកទៀតពី១៩៧៥-៧៨យ៉ាងដូចម្តេចទេ ប៉ុន្តែក្រោយមកគាត់ដឹងថាមានសំលាប់រាប់ម៉ឺននាក់ ។

ប៊ុន ហ៊ីង មានស្រុកកំណើតនៅឃុំចំបក់ ស្រុកបាទី ហើយបច្ចុប្បន្នរស់នៅសហរដ្ឋអាមេរិក បានរាយការណ៍តាមប្រព័ន្ធអ៊ិនធើណែតចំនួនពីរទំព័រផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាថា នៅឆ្នាំ១៩៧៥ មានការសម្លាប់មនុស្សយ៉ាងច្រើននៅវត្តកកោះ ។កាលនោះប្រជាជនដែលបានជម្លៀសចេញពីទីក្រុងភ្នំពេញ ហើយធ្វើដំណើរឆ្លងកាត់តាមផ្លូវជាតិលេខ២ និង លេខ៣ ត្រូវបានកៀរបញ្ចូលមកកាន់វត្តសុរភី ហៅកកោះ មួយចំនួន និង ទៅកាន់វត្តទ្រព្យគរមួយចំនួន ។ ប្រជាជនជម្លៀសទាំងនោះមិនត្រូវបានរួចខ្លួនពីស្លាប់ឡើយ ។ កន្លែងសម្លាប់ស្ថិតនៅក្នុងស្រះទឹកជុំវិញព្រះវិហារវត្តកកោះខាងជើង, ខាងកើត និង ខាងត្បូង ។ ស្រះទឹកនោះមានទំហំប្រមាណជា៥០ម៉ែត្រជំរៅប្រហែល៤ម៉ែត្រ ។ សាកសពដែលបានស្លាប់នៅក្នុងស្រះទឹកនោះមាន ទាំង ក្មេង ចាស់ ប្រុស ស្រី ប្រមាណពី៦ទៅ៧ម៉ឺននាក់ ។ សាកសពគរលើគ្នារហូតមានកំពស់ប្រមាណ ២ ម៉ែត្រឡើងលើ ។ ការសម្លាប់មនុស្សនាពេលនោះ(១៩៧៥) ប្រព្រឹត្តិទៅចាប់ពីថ្ងៃទី១៨ រហូតដល់ ថ្ងៃទី២៥ ខែមេសា ។ **ប៊ុន ហ៊ីង** បានគិតថាឈ្មោះ អ៊ុយ មេបញ្ជាការរងភូមិភាគនិរតីជាអ្នកសម្លាប់ច្រើនជាងគេ ។

ការធ្វើទារុណកម្ម និងសម្លាប់នៅវត្តកកោះមិនបានបញ្ឈប់ភ្លាមៗនោះទេ ។ ពីឆ្នាំ១៩៧៦ដល់ចុងឆ្នាំ១៩៧៨ ក៏នៅតែមានការសម្លាប់មនុស្សយ៉ាងច្រើនដដែល ។ លោកពូ ទឹម គុណ និង មុយ ចក់

ដែលបានជាប់គុកនៅវត្តកកោះតាំងពីឆ្នាំ១៩៧៦ដល់ចុងឆ្នាំ១៩៧៨ បានប្រាប់ថាទីតាំងសម្លាប់ស្ថិតនេះ ខាងកើត ខាងលិច ខាងកើត ខាងជើង និង ខាងត្បូងព្រះវិហារវត្តសុរភី ហៅ កកោះ ក្នុងបរិវេណសាលាបឋមសិក្សាសុរភី និងមាត់ត្រពាំងខាងជើងសាលារៀន ។ ការសម្លាប់មនុស្សច្រើនប្រព្រឹត្តទៅនៅម៉ោង ៣ រសៀលឡើងទៅដោយមាន ចាក់ភ្លេងបន្ទប់អ្នកស្រុកផង។ ការសម្លាប់ភាគច្រើនគឺប្រើដំបង, ត្បូងចប និងដែកក្ងោរទេះជាឧបករណ៍សម្លាប់ ។ នៅឆ្នាំ១៩៧៨ មានការសម្លាប់មនុស្សច្រើនបំផុតមុនពេលមានការផ្លាស់ប្តូរប្រធានសមមិត្ត ពុត ចេញដោយជំនួសវិញនូវឈ្មោះ កន។ ពុត ត្រូវបានដកចេញពីមន្ទីរនៃវត្តកកោះព្រោះរឿងខូចសីលធម៌ជាមួយនារីម្នាក់ ។ សមមិត្ត កន ជាប្អូនរបស់គណៈស្រុកបាទីឈ្មោះសមមិត្ត ជីម ។ ក្នុងពេលដែលសមមិត្ត ពុត នៅគ្រប់គ្រងមន្ទីរសន្តិសុខ និង កន្លែងសម្លាប់វត្តកកោះ គណៈស្រុកមិត្ត ជីម បានដាក់ឲ្យមានផែនការសម្លាប់មនុស្ស ។ លោកពូមុយ ចក់ បានប្រាប់ថានៅពេលដែលគណៈស្រុកមិត្ត ជីម ជិះម៉ូតូសេអឹល៩០ពណ៌ក្រហមចូលមក កាន់វត្តកកោះម្តងៗ និងក្រោយពេលដែលមិត្ត ជីម ចេញទៅវិញគឺប្រាកដជាមានការកោះហៅអ្នកទោសមកសួរ ចម្លើយហើយសម្លាប់ភ្លាមៗ ។ ការសួរចម្លើយនោះមិនមែនសួរពីប្រវត្តិធ្វើការពីមុនទេ ។ តុសួចម្លើយស្ថិតនៅចម្ងាយ៥ម៉ែត្រពីរណ្តៅដែលត្រូវសម្លាប់ ។ ពេលសួរចម្លើយ ពុត មានបញ្ជីមួយបើកមើលថា តើឈ្មោះអ្នកណាខ្លះត្រូវសម្លាប់ និង ឈ្មោះអ្នកណាខ្លះដែលត្រូវទុកបំរើការឲ្យអង្គការតទៅទៀត? ។ បើតាមសំដីរបស់មុយ ចក់ថាបញ្ជីនោះមានកំរាស់ប្រហែល៥-៦ហ៊ុន ហើយឈ្មោះដែលត្រូវសម្លាប់ត្រូវបានគូសដោយប៊ិចក្រហមពីលើឈ្មោះ ឬមានគូសសញ្ញាខ្វែងជើងក្អែកនៅខាងចុងឈ្មោះនោះដោយប៊ិចក្រហមដដែល ។ មុយ ចក់បានបន្តថាឈ្មោះនៅក្នុងបញ្ជីនោះសុទ្ធតែបានកត់បញ្ចូលតាមរបាយការណ៍ របស់ប្រធានភូមិ ឬគណៈឃុំមុនពេលបញ្ជូនអ្នកទាំងនោះមកកាន់មន្ទីរវត្តកកោះ ឬមន្ទីរ០៨ ។ បន្ទាប់មកបញ្ជីនេះបានបញ្ជូនទៅកាន់មន្ទីរស្រុកតាមរយៈគណៈស្រុកឈ្មោះ ជីម ។ មុយ ចក់ក៏បានបញ្ជាក់បន្ថែមថា សញ្ញាខ្វែងជើងក្អែកឬគូសពីលើឈ្មោះដោយប៊ិចក្រហមនេះជាស្នាដៃផ្ទាល់របស់គណៈស្រុកមិត្ត ជីម ។ បន្ទាប់ពីគូសរួចក៏ត្រូវបញ្ជូនមកកាន់មន្ទីរ០៨វិញ ដោយមានឈ្មោះស្រ៊ួ អនុប្រធានគុក០៨ជាអ្នកកាន់បញ្ជី ចំណែកអ្នកសម្លាប់អ្នកទោសគឺជាកងឈ្លបប្រចាំនៅគុកវត្តកកោះ ។ ប្រពន្ធ័សម្លាប់មនុស្សរបស់សមមិត្ត ពុត នាពេលនោះ (ចុងឆ្នាំ ១៩៧៦-៧៨) គឺចងមុខ ចងស្លាបសេករួចត្រូវបញ្ជូនទៅឲ្យលត់ជង្គង់នៅមាត់រណ្តៅ ។ ជុំវិញរណ្តៅនិមួយៗសង្កេតឃើញមានដែកក្ងោរទេះដោតប្រួងប្រាងជុំវិញមាត់រណ្តៅ ព្រមទាំងមានកងឈ្លបឈរត្រៀមចាំសម្លាប់នៅអែបៗនឹងដែកក្ងោរទេះនោះ ។ ការសម្លាប់មនុស្សប្រព្រឹត្តទៅស្ទើរតែរាល់ថ្ងៃដែលមានមនុស្ស

ស្លាប់ចាប់ពី៥០-១០០នាក់ក្នុងថ្ងៃដែលសម្លាប់នោះ ។ ចំនួនរណ្តៅសរុបទាំងអស់ចំនួនរាប់ពាន់រណ្តៅទាំងតូច-ធំ ។ មុយ ចក់បានរាយការណ៍ថា សាកសពចំនួន២០០០០នាក់ជាចំនួនសាកសពរួមពីឆ្នាំ១៩៧៦ដល់១៩៧៨ ។ អ្នកទោសទាំងអស់ស្លាប់ស្ទើរគ្មានសល់ ។ ចំណែកអ្នកដែលនៅរស់រហូតដល់បច្ចុប្បន្នដូចជា លោកពូ មុយ ចក់ ព្រមទាំងមិត្តភក្ត្រ័ ប៉ុន្មាននាក់ទៀត, តាមពិតមិនមែនជាអ្នកទោសដែលមានឈ្មោះនៅក្នុងបញ្ជីរបស់ ពុត ទេ ។ មូលហេតុដែលគាត់ចូលមកកាន់មន្ទីរនេះ ដោយសារមានការចាប់ច្រឡំឈ្មោះ ។ ពួកគាត់ទាំង៦នាក់ មិនត្រូវបានដោះលែងឲ្យរួចខ្លួនមកផ្ទះវិញទេ គឺបានត្រឹមតែមានការដើរហើរនៅក្នុងបរិវេណមន្ទីរសន្តិសុខ១០៨នេះក្រោម ការបញ្ជារពីប្រធានគុកដែលប្រើឲ្យធ្វើនេះធ្វើនោះសំរាប់ពួកគេដូចជា បេះដូង គៀបត្នោត, កាប់ដី, កាប់ឈើ ។ល ។

មន្ទីរសន្តិសុខនេះនៅតែបន្តសកម្មភាពរហូតដិតដល់ថ្ងៃ៧មករា ឆ្នាំ១៩៧៩ដែលពេលនោះកងឈ្លបប្រធាន និង អនុប្រធានគុក នោះបានប្រជុំគ្នាដើម្បីរត់យករួចខ្លួន ។ ចំណែកអ្នកនៅសល់ពីស្លាប់ក៏ត្រូវបានបែកផ្លូវគ្នាវិលទៅរកគ្រួសាររៀងៗខ្លួន ។ វតកកោះនោះបានទទួលរងនូវការខូចខាតយ៉ាងដំណំ ។ ព្រះតេជគុណ កែវ កុសល ព្រះជន្ម២៥ព្រះវស្សាដែលបានបួសតាំងពីឆ្នាំ១៩៩៣នៅវត្តកកោះនេះ ហើយបានពុតាមពុទ្ធដីការរបស់ព្រះគ្រូព្រះនាម សូរ សាត់(សុគត)ថា វត្តនេះ ពិសេសក្នុងព្រះវិហារវត្តមានឈាមកំរ៉ាស់ប្រហែល២ហ៊ុនក្រាលពីលើកំរ៉ាលឥដ្ឋមុខពុទ្ធដិមាករបាក់បែក ។ នៅតាមជញ្ជាំងព្រះវិហារវត្តទាំងសងខាងមានស្នាមចោះទំលុះជញ្ជាំងដើម្បីសិករនុកដែលដាក់ខ្នោះកជើងអ្នកទោស ។ សព្វថ្ងៃព្រះវិហារវត្តនេះនៅបន្សល់ទុកស្លាកស្នាមយ៉ាងច្បាស់ក្រឡែតនូវស្នាមប៉ះស៊ីម៉ងត៍ថ្មីៗគ្រប់រន្ធ និងមានខ្នោះជាច្រើនដាក់តំកល់ក្នុងបូជនីយដ្ឋានមួយជាមួយអដ្ឋិធាតុមួយចំនួនតូច ដែលត្រូវបានគាស់ដោយប្រជាជននៅជុំវិញបរិវេណវត្តនៅក្នុងឆ្នាំ១៩៨០ ។ ពុទ្ធដីការរបស់ព្រះតេជគុណ កែវ កុសល ថាអដ្ឋិធាតុដែលបានគាស់រួចមកនេះស្មើនឹងមួយភាគប្រាំនៃឆ្អឹងទាំងអស់ ។ កន្លែងតំកល់អដ្ឋិធាតុ ស្ថិតនៅខាងកើតឈៀងខាងត្បូងព្រះវិហារវត្តកកោះ ។ នៅថ្ងៃ២០ ឧសភា ស្ទើរតែរាល់ឆ្នាំមានព្រះសង្ឃ១០០អង្គ ព្រមទាំងប្រជាជនរាប់ពាន់នាក់ក្នុងស្រុកមកធ្វើបុណ្យខទ្ទិសកុសល បង្សុកូលជូនដល់វិញ្ញាណក្ខន្ធ័អ្នកដែលបានស្លាប់ទាំងនោះឲ្យទៅកាន់សុគតិភព ។ ថ្មីៗនេះព្រះតេជគុណអង្គនោះបានសាងសង់កុដិមួយនៅក្បែរអតីតរណ្តៅសាកសពទាំងនោះ ហើយព្រះតេជគុណបានជីកដីនៅក្បែរនោះមកតំកល់ជើងតាង ។ នៅពេលដែលជីកបានប្រមាណជិរ៉ៅកន្លះម៉ែត្រ និងទំហំប្រហែលកន្លះម៉ែត្រ ក៏បានប្រទះឃើញមានខោអាវដែលមិនទាន់ពុកផុយ ព្រមទាំងមានឆ្អឹងមួយចំនួនទៀត ។ ឆ្អឹងនោះមានចំនួនជិតមួយបង្គីរ ភាគច្រើនជាឆ្អឹងស្មងជើង និងឆ្អឹងដើមដៃ....។ ព្រះ

គេជគុណនឹងធ្វើការដុះលៀងឆ្អឹងទាំងនោះឲ្យស្អាតរួចយកទៅដាក់នៅក្នុងកន្លែងតំកល់អដ្ឋិធាតុ ដើម្បីបញ្ជាក់ថានៅក្នុងជីពិតជាមាននៅសល់ឆ្អឹងច្រើនទៀតដែលមិនទាន់បានគាស់ ។ យប់ថ្ងៃដដែលនោះក៏មានព្រះសង្ឃអង្គផ្សេងស្រមៃឃើញស្មើរនឹងភ្នែកស្រស់ទាំងកណ្តាលយប់នូវហ្វូងមនុស្សទាំងប្រុស ស្រី ចាស់ ក្មេងនាំគ្នាដើរឡើងសំដៅទៅកាន់ព្រះវិហារវត្តកកោះ ។ ព្រះសង្ឃ កែវ កុសល មានពុទ្ធដីការថាជាព្រលឹងដែលមិនទាន់ស្ងប់របស់ជនរងគ្រោះដើរទាមទារឲ្យមានការសងសឹង ។ ប៉ុន្តែព្រះសង្ឃអង្គនោះក៏បានបញ្ជាក់ ដែរថាមិនបាច់ឲ្យមានការសងសឹងទេ គ្រាន់តែចង់បាននូវការធ្វើបុណ្យជូនអ្នកទាំងនោះទៅជាការស្រេចហើយ ។

## ទីតាំងសម្លាប់នៅវត្តទ្រព្យគរ ភូមិត្រកៀត ឃុំត្រពាំងសាប ស្រុកបាទី

វត្តទ្រព្យគរ ស្ថិតនៅតាមផ្លូវគ្រួសក្រហមមួយខ្សែដែលលាតសន្ធឹងទៅទិសខាងលិចពីផ្លូវជាតិលេខ២ត្រង់ផ្សារសំរោងយ៉ោងឆ្ពោះទៅកាន់ផ្លូវជាតិលេខ៣ត្រង់កាច់ជ្រុងផ្សារត្រាំខ្នារ ។ វត្តនេះកាលពីជំនាន់ ប៉ុល ពត ត្រូវបានខ្មែរក្រហមយកធ្វើជាកន្លែងឃុំឃាំងមនុស្សបណ្តោះអាសន្នមុនពេលយកទៅសម្លាប់ចោល ។ ទីតាំងសម្លាប់ស្ថិតនៅខាងជើងព្រះវិហារវត្តចំងាយប្រហែល៣០០ម៉ែត្រ ។ កន្លែងនោះអ្នកភូមិហៅថាត្រពាំងស្វង និង ត្រពាំងអណ្តូង ។ លោកតា ប្រាក់ អឹម អាយុ៧៨ឆ្នាំ រស់នៅភូមិត្រកៀត ឃុំត្រពាំងសាប ស្រុកបាទី រាយការណ៍ថាមានចំនួន៧៦រណ្តៅនៅទីតាំងទាំងពីរខាងលើ និងមានសាកសពរួមចំនួនរាប់ម៉ឺននាក់ ។ លោកតាបន្តថា ការសម្លាប់មនុស្សនាពេលនោះចាប់ផ្តើមប្រព្រឹត្តទៅនៅឆ្នាំ១៩៧៥ ។ ជនរងគ្រោះ ដែលបានមកស្លាប់នៅទីនេះច្រើនប្រមូលមកពីទីក្រុងភ្នំពេញ និងមកពីឈើទាលជ្រំ ឃុំក្រាំងលាវ ស្រុកបាទី ។ ប្រជាជនបានដឹកមកទាំងឡានៗ មកដាក់បណ្តោះអាសន្ននៅក្នុងបរិវេណវត្តទ្រព្យគរ ។ លោកតាប្រាក់ អឹម មានប្រសាសន៍ថាវត្តទ្រព្យគរមិនមែនជាមន្ទីរសន្តិសុខរបស់ខ្មែរក្រហមទេ ។ នៅឆ្នាំ១៩៧៥ លោកតាបានទទួលបញ្ជាពីប្រធានភូមិឲ្យបិតធាងត្នោតធ្វើជាខ្សែចំណងជាមួយប្រជាជនមួយចំនួនទៀត ។ ខ្សែដែលបិតរួចនោះត្រូវប្រធានភូមិយកទៅទាំងអស់ ។ លោកតាមិនបានដឹងពីមូលហេតុនៃការបិតខ្សែចំណងនោះទេ ។ លោកតាបានបញ្ជាក់ថា នៅពេលថ្ងៃមួយក្នុងឆ្នាំ១៩៧៥ លោកតាបានឃើញកងឈ្លបម្នាក់ដើរកាត់មុខផ្ទះ គាត់ព្រមទាំងបានឃើញកងឈ្លបនោះមានប្រឡាក់ឈាមពេញទាំងខ្លួន ។ លោកតាបានសួរថា«ហេតុអីបានជាឯងប្រឡាក់ឈាមពេញខ្លួនយ៉ាងនេះ?» កងឈ្លបនោះឆ្លើយថា«តាឯងកុំចេះដឹងអី- គេយកមនុស្សទៅសម្លាប់អស់ហើយ» ។ កងឈ្លបរូបនោះបានដោះអាវដែលប្រឡាក់សុទ្ធតែឈាមនោះចេញរួចយកទៅដុតចោល ហើយក៏ប្តូរអាវមួយថ្មីទៀត ។ លោកតានិយាយថាគាត់ភ័យរន្ធត់

យ៉ាងខ្លាំងពេលព្រឹងដូច្នេះ ។ ពេលត្រឡប់មកពីវៃមនុស្សចោលម្តងៗ លោកតាមានប្រសាសន៍ថាគាត់តែងតែសុំរបស់របរផ្សេងៗពីពួកកង ឈ្លបដែលជាអ្នកសម្លាប់មនុស្សទាំងនោះដូចជា ស្បែកជើង ដ្តិលប្រាក់....។ ជួនកាលលោកតាត្រូវបានពួក កងឈ្លបទាំងនោះឲ្យលុយយ៉ាងច្រើន ។ លោកតានិយាយថា«យកលុយមកចាយម៉ែវាអីអញ្ចឹងបើលុយអត់ចាយផង» ។ ក្រោយមកពីរថ្ងៃលោកតាត្រូវបានពួកខ្មែរក្រហមបញ្ជាឲ្យទៅដឹកថ្មនៅភ្នំសារសែយកទៅចាក់នៅឈើទាលជ្រុំ ឃុំក្រាំងលាវចំនួនបីថ្ងៃទើបត្រឡប់មកវិញ ។ ពេលត្រឡប់មកវិញនៅឆ្នាំដដែល(១៩៧៥) លោកតាបានឃើញមានសាកសពដែលកប់មិនជិតយ៉ាងច្រើននៅខាងលិចវត្តទ្រព្យគរចំងាយប្រហែល៣០០ម៉ែត្រ ។ សាកសពត្រូវបានពួកខ្មែរក្រហមតំរៀបផ្កាយក្បាលគ្នានៅក្នុងរណ្តៅ ។ ក្នុងចំនោមទាំង៧៦រណ្តៅនោះមានរណ្តៅចំនួន២ធំជាងគេ ទំហំរបស់វាគឺ ១០ម៉ែត្របួនជ្រុងនិងជំរៅប្រហែល២ម៉ែត្រ ផ្ទុកសាកសពបានជាង៧០គ្រួសារ ក្រៅពីនោះច្រើនជារណ្តៅតូចៗដែលអាចដាក់សាកសពបានត្រឹមមួយគ្រួសារប៉ុណ្ណោះ ។

នៅឆ្នាំ១៩៨០, ប្រជាជនក្នុងភូមិបាននាំគ្នាទៅគាស់កកាយរណ្តៅសាកសពទាំងនោះ ដើម្បីរកមាសនិង វត្ថុមានតំលៃផ្សេងៗ ។ នៅពេលនោះឆ្អឹងមួយចំនួនត្រូវបានចៅហ្វាយស្រុកបញ្ជារឲ្យប្រជាជនរើសយកមកតំកល់នៅក្នុងចេតីយ៍ចំនួន២នៅខាងជើងព្រះវិហារទ្រព្យគរសព្វថ្ងៃនេះ ។ ខ្សែចំណងដែលបានចងអ្នកទោសមិនទាន់ត្រូវបានផុយរលួយទេ ។ លោកតាបានប្រទះឃើញខ្សែចំណងទាំងនោះភាគច្រើនបំផុតជាខ្សែធាងត្នោតដែលក្រុមរបស់លោកតាបានបិតកាលពីឆ្នាំ១៩៧៥[១] នោះ ។

## ទីតាំងមន្ទីរសន្តិសុខនៅវត្តអូរពន្ទ័ ភូមិស្រមោចហែរ ឃុំចំបក់ ស្រុកបាទី

ក្លោងទ្វារវត្តអូរពន្ទ័ ស្ថិតនៅចំងាយ៤៧គីឡូម៉ែត្រពីភ្នំពេញប៉ែកខាងឆ្វេងដៃ (ទិសដៅធ្វើដំណើរពីភ្នំពេញ) ។ ធ្វើដំណើរបន្តចំនួន១៥០០ម៉ែត្រទៀតទើបទៅដល់បរិវេណវត្តអូរពន្ទ័ ។ ទៅដល់ទីនោះ ក្រុម

---

[១] ក្នុងសេចក្តីសំបុត្ររបស់លោក ប៊ុន ហ៊ីងដែលបានផ្ញើតាមប្រព័ន្ធអ៊ិនធើណែតមកមជ្ឈមណ្ឌលឯកសារកម្ពុជា ថាការសម្លាប់មនុស្សនៅវត្តទ្រព្យគរនេះ ស្ថិតនៅក្នុងស្រះទឹកមួយដែលមានទំហំ៧០ម៉ែត្របួនជ្រុង ។ សាកសពមានពេញទាំងស្រះ ហៀរហូររាប់ម៉ឺននាក់ទាំងប្រុស ស្រី ចាស់ ក្មេង ។ ចំណែកឯនៅក្នុងបរិវេណវត្តទ្រព្យគរវិញក៏មានការសម្លាប់ច្រើនទាពាសវាលពាសកាលដែរ ។ លោកប៊ុន ហ៊ីង ក៏បានប៉ាន់ស្មានថា មានសាកសពទាំងអស់ប្រហែលពី៣-៤ម៉ឺននាក់ ។

ស្រាវជ្រាវបានទៅជួបជាមួយព្រះសង្ឃមួយអង្គព្រះនាម ស្វាយ វិត ព្រះជន្ម៦៥ឆ្នាំកំពុងដឹកដីខាងត្បូងព្រះវិហារ ។ ព្រះសង្ឃអង្គនោះមានពុទ្ធដីការប្រាប់ថា ពុំមានការសម្លាប់មនុស្ស ឬ ឃុំឃាំងមនុស្សនៅទីនោះឡើយ ។ ប៉ុន្តែនៅឆ្នាំ១៩៧៨ទីវត្តនេះមានមនុស្សម្នាជាច្រើនមកប្រមូលផ្តុំគ្នាស្នាក់នៅដោយមានបញ្ជាពីពួកខ្មែរក្រហម ។ តាមពុទ្ធដីការព្រះសង្ឃអង្គនោះថា មនុស្សដែលមកប្រមូលផ្តុំគ្នានេះ សុទ្ធតែត្រូវយកមកសម្លាប់ទាំងអស់ ប៉ុន្តែមិនទាន់បានសម្លាប់ផងក៏ត្រូវកងទ័ពវៀតណាមវាយបែកតែម្តងទៅ ។ ប្រជាជនទាំងនោះមានមួយចំនួនធំត្រូវបានស្លាប់នៅក្នុងទីវត្តអូរពង្វ័នេះដោយអត់អាហារ ឬឈឺស្លាប់ ។ សាកសពទាំងនោះបានយកទៅកប់នៅខាងត្បូងព្រះវិហារប្រហែល២០០ម៉ែត្រ ។ នៅជុំវិញព្រះវិហារពួកខ្មែរក្រហមបានជីករណ្តៅធំៗជាច្រើនដើម្បីវាយទំលាក់មនុស្ស ។ ត្រពាំងប្រនៀង ស្ថិតនៅភូមិស្រមោចហែរ ឃុំចំបក់ស្រុកបាទីជាកន្លែងកប់សាកសពប្រជាជនដែលបានស្លាប់ដោយសារជំងឺ ។ សំណង់ដែលបានសង់ឲ្យប្រជាជនទាំងនោះស្នាក់នៅមានរាងជាម៉ារីយ៉េទាហាន (បន្ទាយទាហាន) ។ ព្រះតេជគុណអង្គនោះបានបន្ថែមថាអ្នកដែលបានមកស្នាក់នៅបណ្តោះអាសន្ននៅក្នុងវត្តនេះ សុទ្ធតែជាអ្នកទោសដែលត្រូវបានយកមកពីវត្តព្រទ្បេគរ ព្រោះនៅទីនោះមានការសម្លាប់មិនទាន់ដោយសារប្រជាជនច្រើនពេក ។ ហេតុដូច្នេះទើបមានការបញ្ជូនមកកាន់វត្តអូរពង្វ័ ។ អ្នកទាំងនោះសុទ្ធតែជាអ្នកត្រូវសម្លាប់ទាំងអស់ ។

ខាងក្រោមនេះជាបទសម្ភាសន៍ផ្ទាល់ក្នុងការឆ្លើយបញ្ជាក់ការពិតជាក់ស្តែងរបស់អ្នកដឹងឮ ឬអ្នកទោសផ្ទាល់តែម្តងកាលពីជំនាន់ខ្មែរក្រហមកាន់អំណាចទៅលើទីតាំងទាំងប៉ុន្មានខាងលើដែលបានរៀបរាប់ៈ

## កិច្ចសម្ភាសជាមួយលោកតា សូ ញ៉ៀរ មានដូចខាងក្រោម

ខ្ញុំមានអាយុ៦៩ឆ្នាំ, មានស្រុកកំណើតរស់នៅភូមិកណ្តឹងធំ ឃុំកណ្តឹងធំ ស្រុកបាទី ខេត្តតាកែវ ហើយបច្ចុប្បន្នក៏រស់នៅទីនេះដដែល ។ ខ្ញុំបានជាប់គុកនៅវត្តកកោះ ហៅគុក០៨ភូមិភាគនិរតី តំបន់៣៣ តាំងពីចុងឆ្នាំ១៩៧៣ ។ ខ្ញុំបានរត់ទៅក្រាំងប្រទាល រួចមកវិញក៏ត្រូវគេ(ខ្មែរក្រហម)ចាប់ខ្លួនដាក់គុក ។ អ្នកចាប់ឈ្មោះ ពុត និង ស្រ៊ួ អាយុប្រហែលជាង៣០ ។ ដំបូងនៅពេលដែលខ្ញុំកំពុងទប់ទ្រនប់ធ្វើអន្ទង់ដាក់ត្រីនៅក្នុងស្រែរួមមួយ(ស្រែនៅមុខវត្តកកោះ)ព្រមទាំងដេកចាំជាមួយក្មួយឈ្មោះលាប រួចដុតភ្លើងអាំង ។ នៅពេលនោះមានអាមេក្រុមបានមកផ្លាស់ប្តូរវេនយាម ។ មូលហេតុដែលអាពីរនាក់ (ពុត និង ស្រ៊ួ) មកចាប់ខ្ញុំពេលនោះ ព្រោះខ្ញុំបានដេរទៅពួកវាប្រាប់ទៅក្មួយម្នាក់ទៀតដែលចង់បានត្រីស៊ីដែរ ថា “ត្រីមួយអន្ទង់ដែលដាក់នោះ ត្រូវពួកអាឆ្កែចចកក្បាលខ្មៅស៊ីអស់ហើយ អាហ្នឹងពិបាកប្រដៅវាណាស់ វាបាន

ប្រដៅគេថាមិនឲ្យយកម្ជុលមួយដើម អំបោះមួយសសៃរបស់គេទេ ប៉ុន្តែវាបែរជាយករបស់គេវិញ» ។ ពេលដែលពួកអាពីរនាក់នោះចាប់មកដាក់នៅវត្តកកោះនេះខ្ញុំគិតថាប្រាកដជាស្លាប់ហើយ ។ ពួកគេដាក់ខ្នោះជើងខ្ញុំជាប់នឹងខឿនព្រះវិហារ(ខ្នោះឈើ) ។ កាលនោះមានអ្នកទោសពីរខ្សែជាប់នៅពេលដែលខ្ញុំបានចូលទៅដល់ ។ ក្នុងមួយខ្សែៗមានពី ២០-៣០ នាក់ ។ មានការសម្លាប់មនុស្សខ្លះហើយនៅពេលដែលខ្ញុំមកជាប់នៅវត្តកកោះនេះនៅឆ្នាំ១៩៧៣ ។ ខ្ញុំជាប់នៅវត្តនេះអស់រយៈពេលជាងមួយខែទើបរួចមកវិញ ។ ក្នុងរយៈពេលមួយខែនេះ ខ្ញុំត្រូវពួកខ្មែរក្រហមវៃនឹងសោរកង់ (សោរកង) ចំឆ្អឹងជំនី ។ រហូតដល់សព្វថ្ងៃមិនទាន់បាត់ឈឺផង ។ ប្រធានគុកវត្តកកោះឈ្មោះ ពុត ។ រយៈពេលមួយខែដែលជាប់គុក ខ្ញុំបានឃើញផ្ទាល់ភ្នែកនូវការធ្វើទារុណកម្មវះពោះមនុស្សទាំងរស់មួង និងមានការវៃធ្វើទារុណកម្មស្ទើរតែរាល់ថ្ងៃ ។ អ្នកដែលត្រូវយកមកសម្លាប់ពួកខ្មែរក្រហមប្រាប់ថា «អង្គការឲ្យឡើងទៅតំបន់» ។ អ្នកជាប់គុកពេលនោះគ្រប់ប្រភេទប្រជាជន ទាំងទាហាន, ប្រជាជនថ្មី......... ។ មូលហេតុរួចខ្លួនគឺនៅពេលដែលខ្ញុំកំពុងកាប់ដីនៅដើមឆ្នាំ១៩៧៤ ស្រាប់តែកងឈ្លបដែលនៅទីនោះ(វត្តកកោះ) មកប្រាប់ថា «តាឯងត្រូវអង្គការឲ្យឡើងតំបន់» ពេលនោះខ្ញុំគិតថាពិតជាត្រូវស្លាប់ ។ ពេលមកដល់គុកខ្ញុំបានចូលរួមប្រជុំហើយមិត្ត ពុត ផ្តាំផ្ញើមកខ្ញុំថា«ពេលទៅវិញតាឯងកុំប្រាប់គេឯងថាមានគេវៃ គេមិនឲ្យស៊ីឆ្អែត, ប្រសិនខ្ញុំ(ពុត)ដឹងថានិយាយ ខ្ញុំសម្លាប់ចោលមួយពូជ» ។ អា ពុត, ស្រួ ជាអ្នកប្រាប់ខ្ញុំ ។ របបអាហារគឺ បបរមួយវែកក្នុងមួយពេល បបរសុទ្ធតែទឹកមានលាយគ្រាប់អង្ករមួយគ្រាប់ៗ ។ សម្លរព្រលិតលាយខ្ទោ ។ ពេលបាយមិនដោះខ្នោះចេញទេ ។ពេលបត់ជើងគឺជុះដាក់បំពង់រួចមានអ្នកទោសផ្សេងយកទៅដាក់ស្រែធ្វើជី ។ កាលនោះពុទ្ធដិមាករនៅក្នុងព្រះវិហារមិនទាន់វៃចោលទេ ប៉ុន្តែបន្ទាប់ពីខ្ញុំចេញទើបមានការវៃកំទេច ។ ពួកកងឈ្លប, មេគុកមានស្រុកកំណើតនៅឃុំក្រាំងលាវ ស្រុកបាទី ខេត្តតាកែវ ។ ព្រឹត្តិការណ៍ដែលចាំជានិច្ចគឺពេលដែលខ្ញុំជាប់ខ្នោះរួចត្រូវពួកវាវៃដោយគ្មានសួរនាំអ្វីទាំងអស់ ។

ដើម្បីឲ្យបានច្បាស់ជាងនេះទៀត សូមតាមដានអាននូវសេចក្តីសំបុត្ររបស់ឈ្មោះ ប៊ុន ហ៊ីង ដែលបានផ្ញើសំបុត្រមកមជ្ឈមណ្ឌលឯកសារកម្ពុជាកាលពីឆ្នាំ ១៩៩៨ ។ សេចក្តីសំបុត្រមានដូចខាងក្រោមៈ

ខ្ញុំបាទឈ្មោះ ប៊ុន ហ៊ីង កំណើតនៅឃុំចំបក់ ស្រុកបាទី ខេត្តតាកែវ, បច្ចុប្បន្ននៅទីក្រុងឡូវែល រដ្ឋ ម៉ាស្សាឈូសិត សហរដ្ឋអាមេរិក ។

អំពើឃាតកម្ម ដែលខ្ញុំបានដឹងក្នុងការប្រលយ័ពូជសាសន៍ដែលខ្មែរក្រហមបានសម្លាប់នៅក្នុងស្រុកបាទី ខេត្តតាកែវក្នុងឆ្នាំ១៩៧៥ពេលដែលដេញប្រជាជនចេញពី

ទីក្រុងនោះខ្មែរក្រហមបានចាប់ញយកប្រជាជន ដែលធ្វើដំណើរតាមផ្លូវជាតិលេខ២ និងលេខ៣ យកទៅវាយសម្លាប់ជាច្រើនឥតគណនា ដែលខ្ញុំបានដឹងច្បាស់តាមកន្លែងខ្លះៗដូចតទៅៈ

នៅក្នុងវត្តកកោះ ឃុំកណ្តឹង មានស្រះទឹកមួយពទ្ធ័ជុំវិញព្រះវិហារពីខាងជើង ខាងកើត និងខាងត្បូង ដែលមានទទឹងប្រមាណជា៥០ម៉ែត្រ និងមានជំរៅប្រហែលជា ៤ម៉ែត្រ ។ នោក្នុងស្រះទឹកដ៏ធំនេះ គេឃើញមានសាកសពដែលខ្មែរក្រហមសម្លាប់ទាំងតូច-ធំ-ប្រុស-ស្រី-ចាស់-ក្មេងជាគំនរគរលើគ្នាពេញស្រះទាំងអស់ ហើយមានកំពស់ខ្ពស់ផុតពីស្រះប្រមាណជា២ម៉ែត្រឡើងលើ ដែលសំគាល់បានថាជាសពមនុស្សវាល់ម៉ឺននាក់យកទៅសម្លាប់នៅទីនោះ ។

មួយកន្លែងផ្សេងទៀតនៅវត្តទ្រព្យគរ ក្នុងឃុំត្រពាំងសាប ចន្លោះផ្លូវជាតិលេខ២ និង លេខ៣ ដែលញមានស្រះទឹកមួយទំហំប្រមាណជា៧០ម៉ែត្របួនជ្រុង គេឃើញគំនរសាកសពដែលខ្មែរក្រហមយកទៅសម្លាប់នៅទីនោះ គរលើគ្នាពេញហៀរស្រះ ហើយឃើញមានជាគំនរគរពាសវាលក្បែរទីវត្តនោះទៀតផង ដែលគេសំគាល់ឃើញថាមានចំនួនមនុស្សវាល់ម៉ឺននាក់ទាំងតូច-ធំ-ចាស់-ក្មេង-ប្រុស-ស្រី ត្រូវនាំយកទៅសម្លាប់នៅទីនោះ ។

អំពើឃាដកម្មទាំង២ កន្លែងនេះ បើតាមសំដីរបស់មេគណៈភូមិភាគនិរតីឈ្មោះ អ៊ុយ ជាមេបញ្ជាការវងតាម៉ុក ដែលមានកំណើតកើតនៅឃុំត្រពាំងសាបបាននិយាយរៀបរាប់ប្រាប់ខ្ញុំឲ្យដឹងថា ចំនួនមនុស្សដែលយកទៅសម្លាប់នៅក្នុងវត្តកកោះ ចំនួនប្រហែលជា៦ឬ៧ម៉ឺននាក់រួមទាំងតូច-ធំ-ចាស់-ក្មេង-ស្រី-ប្រុសទាំងអស់ ។ ហើយយកទៅសម្លាប់នៅត្រង់វត្តទ្រព្យគរប្រមាណជា៣ ឬ ៤ ម៉ឺននាក់ប៉ុណ្ណោះដោយ អ៊ុយ បាននិយាយរៀបរាប់ជាអំនួតអួតអាងប្រាប់ខ្ញុំថាអ្នកសម្លាប់ខ្លះ(ឃាតករ) វាយសម្លាប់មនុស្សបានត្រឹមតែ១០ ឬ ២០នាក់ប៉ុណ្ណោះ ត្រូវវិលមុខដួលព្រោះក្រពុលឈាមច្រើនពេក ។ ឯចំណែកខ្ញុំវិញ(អ៊ុយ) វាយសម្លាប់មនុស្សបានក្នុងមួយថ្ងៃចំនួន ១០០ ឬ ២០០នាក់ឥតមានញញើតដៃបន្តិចសោះឡើយ ។

អំពើឃាតកម្ម ដែលខ្មែរក្រហមបានសម្លាប់មនុស្សនៅក្នុងឃុំចំបក់កាលពីឆ្នាំ ១៩៧៥ នោះ ខ្ញុំបានដឹងមាន២កន្លែងទៀតតាមរយៈប្រធានសហករណ៍ឈ្មោះ គង់ (ស្លាប់) ដែលគាត់បាននិយាយរៀបរាប់ប្រាប់ខ្ញុំថាៈ

នៅវត្ត អូរពន្ធ័ ឃុំចំបក់ដដែល គេយកវត្តនោះធ្វើជាមន្ទីរឃុំឃាំងសម្រាប់ឃុំទុកនាយទាហានព្រមទាំងក្រុមគ្រួសារ ដែលមានឋានន្តរសក្ដ័ចាប់ពីអនុសេនីយ៍ត្រីឡើងទៅ, ដែលគេបានស្រាវជ្រាវដឹងថាជាទាហាន ហើយឃុំឃាំងទុកនៅទីវត្តនោះ ។ លុះឃុំទុកបានយូរបន្តិចទើបគេយកទៅសម្លាប់ចោលទាំងអស់ទាំងតូចទាំងធំ-ទាំងប្រុស ទាំងស្រី ដែលមានចំនួន៥ ទៅ៦ពាន់នាក់ អស់រលីងគ្មានសល់ម្នាក់ ។

ហើយនៅភូមិវាល ក្នុងឃុំចំបក់ដដែលគេធ្វើជាមន្ទីរឃុំឃាំងមួយកន្លែងទៀតសម្រាប់ឃុំឃាំងទាហាន ព្រមទាំងក្រុមគ្រួសារដែលគេដឹងថាជាទាហាន ចាប់ត្រឹមពីនាយទាហានរងទៅពលទាហាន ដែលហៅថាពលទោ មានចំនួនប្រហែលជាងមួយម៉ឺននាក់ ទាំងក្មេង-ចាស់-ប្រុស-ស្រី-តូច-ធំ ហើយក្រោយមកគេយកទៅសម្លាប់ចោលទាំងអស់គ្មានសល់មួយ ។

អំពើប្រលយ័ពូជសាសន៍នេះ ខ្ញុំជាខ្មែរមានសេចក្ដីសង្ឃឹមលើលោកសាស្ត្រាចារ្យ ដែលទុកដូចជាទេវតា របស់ខ្មែរដែលលោកអាចជួយបំភ្លឺដល់មតិអន្តរជាតិឲ្យរកយុត្តិធម៌ចំពោះអំពើប្រលយ័ពូជសាសន៍នៃខ្មែរក្រហមដែលជាកម្មុនិស្តក្លែងក្លាយរំលាយពូជអំបូរខ្មែរដែលជាមនុស្សជាតិដូចគ្នា ។

សូមលោកសាស្ត្រាចារ្យមេត្តាទទួលនូវសេចក្ដីគោរព នឹងការមិនភ្លេចគុណអំពីខ្ញុំជាខ្មែរ ។

ឡូវែល, ថ្ងៃទី២៦ ខែឧសភា ឆ្នាំ១៩៩៨

ប៊ុន ហ៊ីង

សំបុត្ររបស់លោក ប៊ុន ហ៊ីងមួយច្បាប់ទៀតបានសរសេរបញ្ជាក់បន្ថែមថា “ការសម្លាប់នេះនៅក្នុងខែមេសា ចន្លោះថ្ងៃ១៨រហូតដល់ថ្ងៃទី២៥មេសាដដែល, ដែលក្នុងពេលនោះខ្មែរក្រហមដេញប្រជាជនចេញពីក្រុងភ្នំពេញ ហើយខ្ញុំត្រឡប់ទៅស្រុកកំណើតរបស់ខ្ញុំវិញ លុះទៅដល់ស្រុកហើយប្រធានភូមិប្រើឲ្យខ្ញុំទៅរើសដែកនៅខាងជើងផ្សារកន្ទួត (ខេត្តកណ្ដាល) ចំនួនគ្នា៥នាក់ ។ កាលខ្ញុំទៅដល់ហួសវត្តស្វែង

បន្តិច ស្រាប់តែមានឡានហ្ស៊ីបមួយមកពីក្រោយខ្ញុំ ហើយចាប់ហ្វ្រាំងង៉ក់រួចមានមនុស្សលោតចុះពីលើឡានស្ទុះមកក្បៀកខ្ញុំជាប់ ធ្វើឲ្យខ្ញុំភិតភយ័តក់ស្លុតស្ទើរបាត់ស្មារតី ទើបមានសម្លេងស្រែកសួរឡើងថា លោកបងឯងខ្លាចអាអ៊ុយ ឬ? ខ្ញុំឆ្លើយថា ឱ! អ៊ុយ ទេតើ ។ ទើប អ៊ុយសួរខ្ញុំថា លោកបងឯងអញ្ជើញទៅណា? ខ្ញុំឆ្លើយថាគេប្រើខ្ញុំឲ្យទៅរើសដែក, អ៊ុយ សួរថាតើរើសដែកធ្វើអី? ខ្ញុំប្រាប់ថាគេឲ្យរើសយកទៅធ្វើធុងដងទឹក និងធ្វើចប ។ អ៊ុយ ថាបើត្រូវការដែកចាំពិបាកទៅឆ្ងាយធ្វើអ្វី នៅនឹងវត្ត ស្វែងនេះហើយ, ខ្ញុំឆ្លើយថា ចុះបើសុទ្ធតែកងយោធាច្រើនម្លេះ, ទើប អ៊ុយ ប្រាប់ថាយោធាក៏មនុស្សដូចយើងដែរ ។

តមក អ៊ុយ ក៏នាំយើងទាំងអស់គ្នាត្រឡប់ចូលទៅវត្តស្វែង ហើយបានបង្ហាញខ្លួនខ្ញុំដល់មេកងយោធាទាំងនោះថា នេះជាបងជីដូនមួយខ្ញុំ, ហើយមេកងទាំងនោះបានទាំងខ្សិបសួរខ្ញុំថា ហេតុម៉េចបានជាស្គាល់តាអ៊ុយ? ខ្ញុំឆ្លើយថា ខ្ញុំស្គាល់ព្រោះ អ៊ុយ កើតនៅភូមិខ្សាច់លប់ ឃុំត្រពាំងសាប ស្រុកបាទីដូចគ្នា ។

បន្ទាប់ក្រោយមក យើងបានឃើញរថយន្ត តាម៉ុក ចូលមកដល់, ពេលនោះ អ៊ុយក៏បានបង្ហាញខ្លួនខ្ញុំប្រាប់តាម៉ុក ថានេះបងជីដូនមួយខ្ញុំ! ទើប ម៉ុក ស្ទុះមកគួរសមនឹងខ្ញុំយ៉ាងរាក់ទាក់ ។ ខ្ញុំនៅទីវត្តស្វែងនេះចំនួន ៥ ថ្ងៃ ហើយបានឃើញ ម៉ុក ចូលមកតែ ២ ដងគត់, បើ អ៊ុយ វិញខ្ញុំឃើញចូលមកជារៀងរាល់ថ្ងៃ ហើយ អ៊ុយ បានផ្តាំផ្ញើនឹងមេកងយោធាទាំងនោះថា ឲ្យជួយរើសដែកគាត់ផង ហើយឲ្យគាត់រើសតែត្រង់ណាដែលយកគ្រាប់ចេញអស់ ។

ក្រោយពេលដែលខ្ញុំចេញពីវត្តស្វែង ខ្ញុំមិនដែលបានជួប អ៊ុយ ទៀតទេ ព្រោះខ្ញុំនៅនឹងស្រុកកំណើតនោះបានតែជាងមួយខែប៉ុណ្ណោះ គេបញ្ជូនខ្ញុំចេញទៅខេត្តបាត់ដំបង ។

## កិច្ចសម្ភាសន៍ជាមួយលោក មុយ ចក់

ខ្ញុំមានស្រុកកំណើតនៅភូមិភ្នំតូច ឃុំត្រពាំងសាប ស្រុកបាទី ខេត្តតាកែវ ។ ជិនាទ់ប៉ុលពតក៏រស់នៅហ្នឹងដែរ ។ ខ្ញុំត្រូវពួកខ្មែរក្រហមចាប់នៅឆ្នាំ១៩៧៦ ចេញពីផ្ទះទៅដាក់នៅសាលាឃុំ ។ ពេលនោះគណៈឃុំឈ្មោះ ប៉េង ស្រែកឲ្យយកទៅដាក់នៅផ្ទះបំបែកមួយជិតសាលាឃុំ ។ ខ្ញុំត្រូវបានយកទៅដាក់នៅក្នុងមន្ទីរឃុំឃាំងមួយនៅចំការដូង ។ ដេកគ្មានកន្ទេលទេ ដេកលើស៊ីម៉ង់ត៍ ។ ខ្ញុំគិតថាពិតជាស្លាប់នៅទីនោះហើយ ។ ខ្ញុំជាប់នៅទីនេះបានតែមួយថ្ងៃទេ លុះព្រឹកឡើងគេឲ្យចេញពីហ្នឹងទៅទៀតដោយមានចងស្លាប

សេកយ៉ាងតឹងទ្រូង ។ មានគ្នាវា(ខ្មែរក្រហម)ជាអ្នកបណ្តើរ ។ លុះទៅដល់សំរោងយ៉ោងបត់ទៅជើង ទៅដល់ក្លោងទ្វារគេបាញ់មួយគ្រាប់ ប្រកាសហៅគ្នាគេ គេអត់ចូលដល់វត្តទេ ។ នៅសល់ដីប្រហែល៣០០ម៉ែត្រទៀត ដីចូលវត្តកកោះ គេបាញ់ផ្លូងទៅលើកំពូលព្រះវិហារ ។ ពួកក្រុមផ្សេងទៀតបានមកយកពួកខ្ញុំ, មកដល់វត្តកកោះនៅម៉ោង១២យប់ ។ ពេលចូលដល់ក្នុងគុក គេឲ្យខ្ញុំដោះខោអាវចេញនៅសល់តែខោខ្លី ព្រោះខ្លាចយើង(អ្នកទោស)ចងករសម្លាប់ខ្លួន ។ គេឲ្យអង្គុយសណ្តូកជើងទៅមុខដើម្បីដាក់ខ្នោះ ។ ខ្នោះនោះធ្វើពីឈើ កាលណាសណ្តូកជើងហើយ គេទំលាក់ខ្នោះនោះពីលើមក បើដាក់ជើងមិនស្រួល គឺត្រូវខ្នោះនោះសង្កត់បាក់កជើង ។ ៧យប់ ៧ថ្ងៃ ខ្ញុំអត់បាយ អត់ចំណី ទឹកក៏អត់ដែរ ផឹកតែទឹកនោមអ្នកទោសដូចគ្នា ។ នៅពេលណាឃើញអ្នកទោសថ្មីៗចូលមក ក៏សុំទឹកនោមអ្នកនោះផឹកមួយក្អឹកម្នាក់ ។ រួចក៏យកមកសួរចម្លើយ ។ ខ្ញុំអត់មានឆក់ខ្សែភ្លើងទេ ប៉ុន្តែអ្នកទោសផ្សេងៗ សុទ្ធតែមានឆក់ខ្សែភ្លើងនៅពេលសួរចម្លើយ ។ បន្ទាប់មកគេលែងខ្ញុំពីព្រះវិហារ ប៉ុន្តែគេឲ្យខ្ញុំនៅធ្វើការក្នុងបរិវេណគុកដូចជា កាប់ដីជាដើម ។ ធ្វើការគេអត់ឲ្យហូបបាយទេ រយៈពេលកន្លះខែគត់ អត់បាយអត់ទឹក ។ ថ្ងៃមួយមានកូនជ្រូករលូតកូនមួយ គេយកទៅបោះចោល ខ្ញុំក៏មានកំលាំងតិចៗចាប់ពីនោះមកក្នុងពេលធ្វើការ ។ បន្ទាប់មកគេចាប់ផ្តើមសួរចម្លើយម្តងទៀតនៅ គោកមុំ (សាលារៀន) ។ ពេលដឹងថាគ្មានឈ្មោះក្នុងបញ្ជី គេសួរថាហេតុអីបានជាមក ខ្ញុំឆ្លើយថាមានគណៈឃុំ ចម គណៈភូមិ សុខ ជាអ្នកចាប់ប្រលំ ។ នៅឆ្នាំ១៩៧៧ គេឲ្យខ្ញុំទៅឡើងត្នោត ពេលនោះខ្ញុំឃើញមានការសម្លាប់មនុស្សរាល់ថ្ងៃ រាប់ពាន់ រាប់ម៉ឺននាក់ ។ គេស្រែកមីក្រូថានៅកន្លែងណា នៅកន្លែងហ្នឹង, បើចូលហើយកុំចេញ បើចេញហើយកុំចូល, បើចេញស្លាប់ បើចូលរស់ ខ្ញុំក៏ទុកចោលត្នោតទាំងខ្ទះៗ ព្រោះកន្លែងនោះជាកន្លែងវៃមនុស្សចោលថ្ងៃ ។ ការងាររបស់ខ្ញុំបន្ទាប់មកមានច្រើនដូចជា ក្រៅពីឡើងត្នោត នៅមានឃ្វាលគោ, រកស្មៅ, កាប់ដីដំបូកអញ្ចឹង ។ អ្នកជាប់នៅមន្ទីរវត្តកកោះនោះភាគច្រើនជាប្រជាជនថ្មី ព្រមទាំងមានអ្នកទោសមកពីគុកសង់ផង ។ គេរំលាយពីមន្ទីរនោះមក នៅសល់ចំនួន១៥០នាក់មកដាក់នៅមន្ទីរកកោះនេះ ។ អ្នកទោសមានយកទៅសម្លាប់ភ្លាមក៏មាន, ទុកយូរសុទ្ធតែជាប្រជាជនចាស់ទេ ។ អ្នកថ្មីអត់មានទុកយូរទេ ។ យកទៅមួយរទេះ វៃមួយរទេះ យកទៅ១០ វៃ ១០ ។ កន្លែងសម្លាប់ស្ថិតនៅខាងលិចវត្ត, ខាងត្បូងវត្តក៏មាន, មុខព្រះវិហារក៏មាន, សាលារៀន(សូរភី)រាល់ថ្ងៃក៏មានដែរ, អាមាត់ត្រពាំងខាងជើងសាលារៀនក៏មាន ។ ពេលគេសម្លាប់ខ្ញុំបានឃើញផ្ទាល់ភ្នែកគឺ គេបណ្តើរមកមានចងស្លាបសេក, ចងមុខក្រម៉ា ។ ពេលនោះ គេ(ពួកខ្មែរក្រហម) និយាយថា “ស្តាប់អង្គការសួរ ទី១, ទី២,....វៃប្រុស ។ អ្នកទោសគេឲ្យអង្គុយលត់ជង្គង់នៅមាត់រណ្តៅ ។ ពេលវាយសម្លាប់រួច ពួកគេដោះយក

ខោអាវចេញ រួចគំរៀបសាកសពផ្ទុយក្បាលគ្នាក្នុងរណ្តៅ ។ វៃភាគច្រើនតែពេលព្រលប់ និយាយរួមចាប់ពីម៉ោង៣រសៀលមក និងមានចាក់ភ្លេងបន្ទប់កុំឲ្យឮសំរែក ហើយដាក់ផ្កាកកុំឲ្យមានការដើរឆ្លងកាត់ ។ ពុតជាអ្នកបញ្ជារឲ្យសម្លាប់ ។ រណ្តៅភាគច្រើនមានទំហំ២ម៉ែត្របួនជ្រុង ជំរៅ២ម៉ែត្រ ។ មានការសម្លាប់ច្រើននៅឆ្នាំ១៩៧៨ ។ ពួកវាវៃសម្លាប់នឹងភ្លៅរទេះ ។ ខ្ញុំឃើញពីលើចុងត្នោតញ៉រដើងទទ្រើតគឺនៅជុំវិញរណ្តៅទាំងបួនជ្រុង គ្នាវា(ពួកខ្មែរក្រហម)ឈរជុំវិញមាត់រណ្តៅ១០នាក់ មានដែកភ្លៅរទេះ១០ដើមដែរនៅក្បែរខ្លួន ។ ជនរងគ្រោះយកទៅអញ្ជើងគឺ ឲ្យអង្គុយលត់ជង្គង់នៅក្បែរភ្លៅរទេះដែលដោតជាប់នឹងដី ។ ពួកវាសម្លាប់រៀងរាល់ថ្ងៃ ក្នុងមួយខែគឺអត់ដែលមានខានថ្ងៃណាឡើយ ។ អ្នកទោសមានលាយចំរុះគ្នា មានទាំងស្រ្តីមានផ្ទៃពោះ,កូនង៉ែត ។ មានស្រ្តីខ្លះត្រូវបានចាប់រំលោភមុនយកទៅសម្លាប់ ។ អ្នកខូចសីលធម៌ខ្លះពេលដែលពួកគេចាប់បានត្រូវសំរក់ជ័រកៅស៊ូពីលើទាល់តែស្លាប់ ។ ចំនួនរណ្តៅមានច្រើនណាស់ប្រហែលរាប់ពាន់រណ្តៅខ្លះ មានទំហំ៤ម៉ែត្របួនជ្រុង, ៣ម៉ែត្របួនជ្រុង ជំរៅ៣ម៉ែត្រទៅក្រោម ។ ក្នុងមួយរណ្តៅៗមានចាប់ពី៥០០នាក់ ។ សាកសពរួម(ពីឆ្នាំ១៩៧៦-៧៨)មានចំនួនប្រហែល២០០០០នាក់ ។ ជនរងគ្រោះប្រមូលមកពីគ្រប់កន្លែងទាំងអស់ ។ អ្នកជាប់ឃុំឃាំងគេគឺអ្នកទោសក្បត់ ។ ចំណែក តាខេន ដែលជាអ្នកជាប់ទោសត្រូវគេវៃហើមក្បាល កាលនោះខ្ញុំជាអ្នកយកបាយឲ្យគាត់ហូប អត់ហូបបបរទេ ។ គេបញ្ជារឲ្យគាត់សរសេរពីបញ្ហានយោបាយឲ្យគេ ។ លុះសរសេរចប់គឺត្រូវយកទៅសម្លាប់ចោល ។

អ្នកជាប់ទោសនៅក្នុងព្រះវិហារមានចំនួនប្រមាណ២០០០នាក់ក្នុងនោះមានផ្នែកស្រីៗ ។ ចំណែកកូនដែលបានកើតមករួចរាប់ក៏ត្រូវបាត់ (ប្រហែលជាហែកកូននោះស៊ីអស់) ព្រោះមិនឃើញយកចេញទៅកប់ទេ,នេះជាសំដីរបស់លោកពូមុយ ចក់ដែលបាននិយាយប្រាប់ក្រុមស្រាវជ្រាវយើង ។ មានយកអ្នកទោសចេញទៅក្រៅ និងយកប្រជាជនថ្មីមកចូលរាល់យប់ ។ អ្នកទាំងនោះច្រើនអ្នកមកពីភ្នំពេញ មានរូបរាបស-ស្អាត ព្រមទាំងមានមនិយាយភាសាអង់គ្លេសទៀត ។ មានជនបរទេសខ្លះ ព្រោះខ្ញុំឃើញឆ្អឹងវែងៗ ឆ្អឹងលលាដ៍ក្បាលធំៗ ។ ជាជនជាតិបារាំង ហើយត្រូវបានកប់តែម្នាក់ឯង ។ មានមេសន្តិសុខ ៣ នាក់គឺ មិត្តពុត, មិត្តស្រ៊ួ និង មិត្តកន ។ មិត្តកនកាន់កាប់បានប្រហែល៣-៤ខែ បន្ទាប់ពីទំលាក់ មិត្តពុត ចេញដោយសាររឿងខុសសីលធម៌ជាមួយនារី ។ មិត្តកន គ្រប់គ្រងនៅឆ្នាំ១៩៧៨ចុងឆ្នាំ ។ មិត្តកនជាប្អូនរបស់គណៈស្រុកមិត្ត ជីម ។ ចំណែក មិត្តប្រិច ជាកងចលត័ ។ អ្នកទាំង៣មាន មិត្តពុត និង មិត្តកន ជាអ្នកសាហាវជាងគេ ។ មានសន្តិសុខ១០នាក់ និងមេ២នាក់គ្រប់គ្រងនៅវត្តកកោះនេះ ។ មានការសម្លាប់ច្រើននៅពាក់កណ្តាលឆ្នាំ១៩៧៨ ។ ក្នុងចំនោមអ្នកទោសទាំងអស់មាននៅសេសសល់តែ៣-៤នាក់ប៉ុណ្ណោះ ។

ពេលវ៉ៃចោល ពួកខ្មែរក្រហមយកបញ្ជីទៅជាមួយ ដាក់នៅលើតុមួយ ។ ពេលយកមនុស្សទៅសម្លាប់គ្មានចង់មុខទេគឺដើរធម្មតា, ទៅដល់កន្លែងតុនោះ ខ្មែរក្រហមឲ្យអង្គុយនោលើតុវែងមួយ (តុក្មេងរៀន) ។ រួចចាប់ផ្តើមសួរចម្លើយតាមគ្រួសារ ដោយដាក់តាមឃុំ ។ ពេលសួរចម្លើយរួច ក៏យកទៅសម្លាប់ចោលអស់ បន្ទាប់មកក៏ទៅយកមួយក្រុមមកទៀត និងធ្វើរបៀបនេះដដែល ។ អ្នកសួរចម្លើយឈ្មោះ ពុត ដែលមានចំងាយ៥ម៉ែត្រពីរណ្តៅ ។ មិត្ត ស្រ៊ួជាអ្នកកាន់បញ្ជីធំ ។ ក្នុងបញ្ជីនោះមានដាក់ទាំងឋានៈផង ដូចជាឈ្មោះអ្នកនេះ អ្នកនោះ ពាក់សក្តិ១-២ ព្រោះមុនពេលចុះឈ្មោះគេបានវ៉ៃសួរចម្លើយសួររកឋានៈដោយប្រាប់ថាឲ្យចេញទៅវិញភ្លាមបន្ទាប់ពីសួររួច, ប្រសិនបើឆ្លើយមិនពិតនឹងត្រូវវ៉ៃច្រកបាវរួចចាក់ទឹកពីលើ ព្រោះឈ្មោះអ្នកទាំងនោះសុទ្ធតែបានរាយការណ៍ម្តងរួចហើយនៅតាមភូមិ-ឃុំ ។ បញ្ជីនេះបានបញ្ជូនទៅកាន់ស្រុក-តំបន់ ដោយមានឈ្មោះមិត្ត ជឹម ជាអ្នកយកទៅ ។ មិត្ត ជឹមជិះម៉ូតូសេអិល៩០ពណ៌ក្រហម ។ កន្លែងសម្លាប់មិនមែនមិត្ត ពុត ជាអ្នកសំរេចទេ គឺបញ្ជារពីគណៈស្រុកមិត្ត ជឹម ។ ឈ្មោះដែលត្រូវសម្លាប់គឺ ខាងគណៈស្រុកបានគូសពីលើឈ្មោះ ឬ យកប៊ិចក្រហមចុចពីលើឈ្មោះ រួចមើលរហូតដល់ចុងបន្ទាត់ទើបគូសខ្វែងលេខបូក ។ អ្នកដែលគូសនោះគឺជាគណៈស្រុក ចំណែកអ្នកហៅមកសួរគឺប្រធានគុកឈ្មោះមិត្ត ពុត ឯអ្នកសម្លាប់វិញគឺកងឈ្លបរបស់ពួកគេ ។ ជឹមនេះមុខមាត់កាចសាហាវណាស់ ។ ឲ្យតែមិត្ត ជឹមមកពេលណាមានមនុស្សស្លាប់ពេលនោះ ។ អ្វីដែលធ្វើឲ្យខ្ញុំនឹកឃើញជានិច្ចនោះគឺពេលដែលគេចាប់ខ្ញុំទាំងគ្មានកំហុស ។ គំនិតរបស់ខ្ញុំនៅពេលជួបមេខ្មែរក្រហមដូចជា ប៉ុល ពត, អៀង សារី, តាម៉ុក ខ្ញុំសួរថា "យ៉ាងម៉េចក៏ចង់សម្លាប់ខ្មែរគ្នាឯង? យ៉ាងម៉េចក៏បង្កបង្កើតខ្មែរក្រហមអញ្ចឹង? តើមានមេធំទៀតទេ?" ខ្ញុំចង់ឲ្យមានតុលាការកាត់ទោសខ្មែរក្រហម ព្រោះពួកវាក្បត់ សម្លាប់ប្រជាជនយ៉ាងរង្គៀល ។ ប្រសិនបើ មេខ្មែរក្រហមត្រូវចាប់ដាក់គុក ខ្ញុំមានអារម្មណ៍សប្បាយចិត្តណាស់ ព្រោះលែងខ្លាចមានការវិលត្រឡប់មកវិញទៀតហើយ ។ ក្រោយការកាត់ទោសខ្ញុំលែងមានអារម្មណ៍ថារបបហ្នឹងត្រឡប់មកវិញទៀតហើយ ។ របបនេះមិនអាចកើតមានជាលើកទី២បានទេ ប្រសិនបើមិនទាន់មានការកាត់ទោសទេ ខ្ញុំជឿថានៅតែមានភាពរប៉ះរប៉ោះអញ្ចឹងដដែល ។

ខាងក្រោមនេះជាពុទ្ធដីការផ្ទាល់របស់ព្រះតេជគុណមួយព្រះអង្គគង់នៅវត្តសូរភី ហៅ កកោះ ។

## កិច្ចសម្ភាសន៍ជាមួយព្រះសង្ឃព្រះនាម កែវ កុសល

អាត្មាព្រះជន្ម២៥វស្សា, បួសនៅវត្តកកោះនៅឆ្នាំ១៩៩៣ ពេលចូលបួសបានឃើញមានឆ្អឹង, មានរណ្តៅសាកសពក្នុងជំនាន់៣ឆ្នាំ ៨ខែ ២០ថ្ងៃ ដែលបន្សល់ទុកនូវឆ្អឹងជាច្រើន ប៉ុន្តែគ្រាន់តែប្រជាជនដើងវត្តនឹកឃើញថាសុទ្ធតែជាសាច់ញាតិ ក៏ត្រូវជាខ្មែរដូចគ្នា ក៏បានប្រម៉ែប្រមូលនូវលលាក្បាលមួយចំនួនមកតំកល់ ដើម្បីឲ្យសាចញាតិមកធ្វើបុណ្យបង្សុកូល-ឧទ្ទិសមគ្គផលទៅឲ្យអ្នកដែលបានស្លាប់ទៅនោះ ហើយមិនតែប៉ុណ្ណោះនៅលើព្រះវិហារ បើតាមពុទ្ធដីការគ្រូរបស់អាត្មាព្រះនាម សូរ សាត់(សុគត) លោកបានមានពុទ្ធដីការប្រាប់អាត្មាថានៅលើព្រះវិហារមានឈាមកំរ៉ាស់ប្រហែលពីរហ៊ុន ។ គ្រូរបស់អាត្មាចូលមកកសាងវត្តនេះដំបូងនៅឆ្នាំ១៩៨០ ឃើញមានឈាមពណ៌ក្រម៉ៅពេញទីព្រះវិហារ ។ មានស្នាកស្នាមចោះខឿនព្រះវិហារដើម្បីដាក់ដែក, ខ្នោះដាក់កជើងរហូតដល់ថ្ងៃបញ្ចេញយកមកសម្លាប់ញ ។ អ្នកជាប់ទោសភាគច្រើនជានិស្សិត,បញ្ញាវន្តខ្មែរដែលត្រូវបានជម្លៀសចេញពីភ្នំពេញ, មានថែមទាំងអ្នករដ្ឋការ, ទាហានប៉ូលីស,ដែលមានសក្តិធំៗ ត្រូវបានបញ្ជូនមកកាន់ទីវត្តនេះទាំងអស់ ។ មានអ្នកខ្លះភយ័ពេកក៏រត់ ប៉ុន្តែត្រូវពួកខ្មែរក្រហមបាញ់សម្លាប់ចោលភ្លាមដែរ ។ អ្នកជាប់នៅមន្ទីរនេះមានចំនួនច្រើនណាស់ អាត្មាមិនអាចរៀបរាប់បានទេ ប្រហែលរាប់ម៉ឺននាក់ឯណោះ ។ ចំនួនក្បាលដែលបានប្រមូលមកដាក់នៅកន្លែងតំកល់អដ្ឋិធាតុនេះបានប្រហែលត្រឹមមួយភាគប្រាំនៃសាកសពទាំងអស់(ក្បាលមួយចំនួន ត្រូវបានប្រមូលមកដាក់នៅកន្លែងតំកល់អដ្ឋិធាតុដែលស្ថិតនៅពីមុខវត្តកកោះ) ។ ចំនែកកន្លែងសម្លាប់គឺស្ថិតនៅខាងជើងក៏មាន ខាងត្បូងក៏មាន ។ ក្នុងមួយរណ្តៅមាន៥ម៉ែត្រខ្លះ ៨ម៉ែត្រខ្លះ ហើយក្នុងមួយរណ្តៅនោះ បើតាមព្រះសពគ្រូអាត្មាថាមានប្រហែលពី៦០-៨០នាក់ ។ចំនួនរណ្តៅមិនអាចរាប់បានទេ ព្រោះច្រើនពេក ។ ប្រហែលជាង៣០០រណ្តៅ ។ ចំនែកត្រពាំងនៅខាងមុខព្រះវិហារចំនួន២នោះ ពួកខ្មែរក្រហមមិនបានសម្លាប់មនុស្សដាក់ទេ មានតែឈាម ព្រមទាំងសាកសពខ្លះធ្លាក់ចូលទៅក្នុងត្រពាំងនេះ, មានសែងដាក់ខ្លះ ។ ស្រះនៅមិនអាចប្រើប្រាស់ទឹកបានទេ ទើបតែនៅឆ្នាំ១៩៩០ ទើបអាចប្រើបាន ព្រោះមានប្រជាជនមកស្តារស្រះទឹកនេះចេញ ។ ពេលស្តារមានជួបប្រទះឆ្អឹងច្រើន ហើយបានប្រមូលយកមកដាក់តំកល់នៅកន្លែងតំកល់អដ្ឋិធាតុ ។ សាកសពទាំងអស់ អាត្មាមិនអាចរៀបរាប់បានទេ ព្រោះច្រើនពេក ។ ទំហំរណ្តៅមានជំរៅ ២ម៉ែត្រ និងមានទំហំ៣-៤ម៉ែត្រ ។ វិធីសម្លាប់ច្រើនវ៉ៃនឹងត្បូងចប, កាំភ្លើង, កាំបិត, ពូថៅ, .....។ ឆ្អឹងលលាក្បាលដែលបានគាស់រួចមកនេះគ្រាន់តែជាតំណាងនៃការស្លាប់ប្រជាជនខ្មែរក្នុងរបបប៉ុល ពត ។ នៅថ្ងៃ២០ ឧសភា ខាងរដ្ឋាភិបាលបានមកធ្វើបុណ្យឧទ្ទិសមគ្គផល, រាប់បាតព្រះសង្ឃ១០០អង្គ ព្រមទាំងពុទ្ធបរិសទ័ជាច្រើនបានមកចូលរួមធ្វើបុណ្យ ។ ចំនែកស្នាមចោះទំលុះខឿនព្រះវិហារ ដើម្បីដាក់រនុកដែកតាមខ្នោះ

សព្វថ្ងៃត្រូវបានជួសជុល ប៉ុន្តែនៅមានស្នាកស្នាម ។ អាត្មាបានជីកដីខាងត្បូងព្រះវិហារ(អតីតរណ្តៅសាកសពជំនាន់ប៉ុល ពត) យកអាចម៍ដីទៅដាក់តំកល់ជើងតាងធ្វើកុដិសំរាប់ព្រះសង្ឃស្នាក់នៅ ប្រហែលកន្លះម៉ែត្រជំរៅ និង ទំហឹកន្លះម៉ែត្រ ក៏បានឃើញឆ្អឹងព្រមទាំងខោអាវ ។ ឆ្អឹងទាំងនោះអាត្មាប្រមូលបានជិតមួយបង្គីរ ។ ឆ្អឹងទាំងនោះអាត្មាបានចាក់ទៅក្នុងរណ្តៅនោះវិញ ព្រោះខ្វះបង្គីរប្រើការ ។ អាត្មានឹងឲ្យកូនសិស្សអាត្មារើសយកមកលៀងទឹកដើម្បីយកទៅដាក់នៅកន្លែងតំកល់នៅពេលក្រោយការងារ ។ អាត្មាមិនអាចជីកតទៅទៀតបានទេ ព្រោះកន្លែងនោះ (អតីតកន្លែងកប់សាកសព) ត្រូវបានគ្រូអាត្មាដាំដើមដូងពីលើរណ្តៅទាំងនោះ (នៅឆ្នាំ១៩៨០) អស់ហើយ ។ ឆ្អឹងដែលជីកបាននោះមានឆ្អឹងស្មងជើង, ឆ្អឹងកដៃ, ឆ្អឹងកំភួនដៃជង...។ បេលគាស់នោះមានឃើញខោអាវជនរងគ្រោះនៅមិនទាន់រលួយទេ ព្រមទាំងអាត្មាបានទាញចេញពីរណ្តៅមកដាក់ចោលនៅលើដីដូចឃើញស្រាប់ ។ ជុំវិញព្រះវិហារមានស្រះទឹកចំនួន៣ស្ថិតនៅខាងជើង, ខាងកើត, ខាងត្បូង ។ ឆ្អឹងជាភស្តុតាងមួយ បើយើងដុតចោលមិនបានការទេ ប៉ុន្តែយើងទុកសំរាប់ក្មេងស្រករក្រោយ ដើម្បីឲ្យក្មេងនោះដឹងថាជំនាន់មុននោះ (ជំនាន់ប៉ុលពត) មានទារុណកម្មកើតឡើងមកលើប្រជាជនខ្មែរ ។ បើកាលណានិយាយប្រាប់តែមាត់ទទេរវា(ក្មេងៗ) មិនជឿទេប៉ុន្តែបើមានភស្តុតាងអញ្ចឹងទើបវាជឿយើងនិយាយ ។ បើនិយាយតាមផ្លូវព្រះពុទ្ធសាសនាវិញគឺវិញ្ញាណក្ខន្ធ័របស់សាកសពនោះវិលវល់ទាំងអស់ពេលដែលសាកសពដែលបានស្លាប់នោះ ស្លាប់ដោយគ្មានហេតុ (ស្លាប់តែហោង ឬស្លាប់ដោយគ្មានធម៌អារ័ក្នុងខ្លួន) ដោយជំនាន់ប៉ុល ពតសម្លាប់ឥតមេត្តា, វ៉ៃដោយដងចប, កាំបិត........។ អាត្មាចូលមកវត្តនេះយូរហើយមិនដែលភយ័ខ្លាចទេ ប៉ុន្តែពេលដែលគាស់ទៅឃើញឆ្អឹងក៏មានការព្រឺព្រួចពេញខ្លួន ហើយមានព្រះសង្ឃអង្គផ្សេងមួយអង្គទៀតដែលគង់នៅលើព្រះវិហារបានឃើញខប្បន្ទុវហេតុទាំងកណ្តាលយប់ប្រហែលជាម៉ោង១ ឃើញមានហ្វូងមនុស្សដើរឈូឆរពេញទីធ្លាវត្ត រួចឆ្កែក៏លូរទ្រហឹងពេញវត្ត ។ ហ្វូងប្រជាជនទាំងនោះបានដើរទៅលើព្រះវិហារ ។ លោកអង្គនោះឃើញតែមួយភ្លែតក៏បាត់ទៅវិញ, អាត្មាគ្រាន់តែចង់ឲ្យបងប្អូនទូទៅផ្តួចផ្តើមធ្វើបុណ្យ ដើម្បីខទ្ទឹសកុសលផ្ញើទៅឲ្យវិញ្ញាណក័ន្ធទាំងនោះដើម្បីឲ្យវិញ្ញាណក័ន្ធទាំងនោះឆ្ពោះទៅកាន់កន្លែងសុខ សុគតិភពកុំឲ្យនៅតែមានការវិលវល់របៀបនេះ ។ ចំពោះសកម្មភាពដែលសង្ឃអង្គនោះបានឃើញនាពាក់កណ្តាលយប់នោះ បើតាមអាត្មាយល់គឺចង់សងសឹក, ប៉ុន្តែយើងអាចធ្វើបុណ្យវិញ មិនបាច់ឲ្យវិញ្ញាណកន្ធ័អ្នកទាំងនោះចង់សងសឹកទេ ព្រោះបានធ្វើបុណ្យបញ្ជូនទៅហើយ ។ មូលហេតុដែលព្រលឹងអ្នកទាំងនោះដើរតំរង់ទៅរកព្រះវិហារ ព្រោះថាបើតាមលោកអាចារ្យដែលជាអាចារ្យខ្មោចនិយាយថាប្រសិនបើអ្នកដែលស្លាប់នោះ ស្លាប់នៅទីណា តែងតែវិញ្ញាណក្ខន្ធ័នោះវិលវល់

ទីនោះ ។ អញ្ចឹងសាកសពនោះអញ្ចឹងដែរ ។ មូលហេតុដែលវិញ្ញាណក្ខន្ធ័ទាំងនោះនៅវិលវល់ ព្រោះពួកគេចង់ឲ្យអ្នកដែលរស់នៅ ជាពិសេសដែលត្រូវជាសាច់ញាតិធ្វើបុណ្យបញ្ជូនឲ្យពួកគេ ។

### កិច្ចសម្ភាសន៍ជាមួយលោកតា ស៊ិន ស៊ុំ

ខ្ញុំអាយុ៦៨ឆ្នាំ មានស្រុកកំណើតនៅភូមិត្រកៀត ឃុំត្រពាំងសាប ស្រុកបាទី ខេតតាកែវ ។ សម័យប៉ុលពត និង បច្ចុប្បន្នក៏រស់នៅទីនេះដដែល ។ ជំនាន់ប៉ុលពត មានតែការសម្លាប់ប្រជាជន, ឲ្យធ្វើការមិនឲ្យហូបបាយ, ហូបតែបបរ ។ បបរមួយខ្ទះ មានអង្ករតែ២កំប៉ុង ។ វត្តទ្រព្យគរនេះ ពួកខ្មែរក្រហមគ្រាន់តែយកធ្វើជាកន្លែងឃុំឃាំងបណ្តោះអាសន្នប៉ុណ្ណោះ, ត្រឹមតែ២-៣ថ្ងៃគឺយកទៅវៃចោលហើយ ។ ប្រជាជនដែលយកមកឃុំឃាំងមុនសម្លាប់នៅវត្តនេះ ភាគច្រើនតែអ្នកធ្វើការ, ទាហានសក្ត៍១-២ ភាគច្រើនយកមកពីតំបន់យោលទោង ដោយដឹកតាមឡាន ។ មនុស្សដែលត្រូវយកមកសម្លាប់គឺស្ថិតនៅត្រពាំងស្នួ ភូមិត្រកៀត ឃុំត្រពាំងសាប,មានចំនួនរាប់រយរណ្តៅ ដែលមានរណ្តៅធំ១នោះដាក់សាកសពចំនួន៧០គ្រួសារ ទំហំទទឹង១៩ បណ្តោយ២០ និង ជំរៅ១០ម៉ែត្រ, នៅមានរណ្តៅតូចៗដាក់សាកសពពី១-២គ្រួសារជាច្រើនទៀត ។ ដីដែលពួកខ្មែរក្រហមយកធ្វើជាកន្លែងកប់ខ្មោចមានទំហំប្រហែលជាកន្លះគីឡូម៉ែត្របួនជ្រុង ។ មនុស្សដែលបានស្លាប់នៅទីនោះមានចំនួនប្រហែល ៥០០០នាក់ ។ សម្លាប់នៅឆ្នាំ១៩៧៥-៧៦ ។ យកមកដំបូងគឺត្រូវស្តុបទុកនៅទីធ្លាវត្តទ្រព្យគរសិន ។ ដល់ពេលបិតចំណងបានគ្រប់គ្រាន់ទើបពួកខ្មែរក្រហមចងប្រជាជនទាំងនោះបញ្ជូនទៅសម្លាប់តែម្តង ។ អ្នកកាន់មន្ទីរវត្តនិងទីតាំងសម្លាប់នោះមានឈ្មោះ តាភឿង ។ ការសម្លាប់មនុស្សធ្វើឡើងនៅពេលព្រលប់, ជួនកាលមាន់រងាវជិតភ្លឺ ។

ដើម្បីឲ្យច្បាស់ជាងនេះទៅទៀត សូមតាមដានស្តាប់នូវការសម្ភាសន៍ជាមួយលោកតាម្នាក់ទៀតឈ្មោះ ប្រាក់ អ៊ឹម ។

### កិច្ចសម្ភាសន៍ជាមួយលោកតា ប្រាក់ អ៊ឹម

ខ្ញុំមានអាយុ៧៨ឆ្នាំ, មានស្រុកកំណើតនៅភូមិត្រកៀត ឃុំត្រពាំងសាប ស្រុកបាទី ។ ជំនាន់ប៉ុលពតក៏រស់នៅហ្នឹងដែរ ។ ខ្ញុំបានមកបិតខ្សែធាងត្នោតឲ្យពួកខ្មែរក្រហមនៅឆ្នាំ១៩៧៥ ។ ពេលដែលកំពុងបិតខ្ញុំបានឃើញមានឡានដឹកមនុស្សជាច្រើនចូលមកកាន់វត្តទ្រព្យគរ ។ ឡានចូលមកចេះតែបាត់ៗ ពេលនោះខ្សែដែលបានបិតរួច ក៏ត្រូវប្រធានភូមិលីយកទៅ រួចខ្ញុំចេះតែបិតតទៅទៀត ។ អ្នកបិតខ្សែធាងត្នោតមានគ្នា២០-៣០នាក់ឯណោះ ។ ប្រជាជនដែលដឹកចូលមកនោះមានដឹងតាមឡាន, រទេះគោ, ដើរ...... ។

ប្រជាជនមូលដ្ឋានមិនអនុញ្ញាតិឲ្យចេញពីផ្ទះទេ។ ប្រជាជនដែលដឹកចូលមកនោះ ពួកគេនិយាយថាមកសន្និបាតនៅវត្តទ្រព្យគរ។ រណ្តៅមាន៧៦រណ្តៅ ក្នុងនោះមានរណ្តៅធំចំនួនពីរ។ នៅពេលយប់ ឃើញពួកកងឈ្លបយកស្បែកជើងកៅស៊ូ។ តើគេយកទៅណា? - នែហ៎ា តាឯងកុំដឹង(សំដីរបស់កងឈ្លបម្នាក់នោះ)។ ស្រាប់តែឃើញប្រឡាក់ឈាម- អូ៎ា ប្រឡាក់ឈាមមុខ កុនហើយអញ្ចឹង, នែហ៎ ឯងធ្វើអីហ្នឹង (អ៊ឹមសួរទៅកងឈ្លប) - នែហ៎ តាឯងកុំដឹងអីនៅឲ្យស្ងៀមទៅ, តើឯងសម្លាប់គេទេឬ បើទៅបាត់ៗ? មួយសន្ទុះមកក៏ឃើញអាម្នាក់នៅជ្រលង (ឃុំជ្រលង) កាន់ប្រាក់សរមករួចសួថាតើគេយកមនុស្សទៅណា (បុរសម្នាក់នៅឃុំជ្រលងប្រាប់ថា) គេយកទៅសម្លាប់អស់ហើយនៅឯជើងវត្ត, អ្ហែស៎ា ឲ្យស្បែកជើងគ្នាមួយសំរាប់មក(តាអ៊ឹមនិយាយ)។ ឯងចុចពិលមើលឃើញអាវសុទ្ធតែឈាម, វាដោះអាវពាក់នោះដុតចោលនៅមុខផ្ទះរបស់ខ្ញុំ រួចផ្លាស់អាវថ្មី ។នៅដើមឆ្នាំ១៩៧៥, គេយកទៅវៃចោលអស់ហើយ រួចវាហុចលុយឲ្យខ្ញុំសន្ទឹក។ ខ្ញុំនិយាយថា យកចាយម៉ែវាអិអញ្ចឹង៎ា បើលុយអត់ចាយផង។ ក្រោយមកពីរថ្ងៃ ខ្ញុំត្រូវទៅដឹកថ្មពីភ្នំសាសែទៅចាក់នៅឈើទាលជ្រុំ ឃុំក្រាំងលាវ។ អស់ចំនួន៣-៤យប់ រួចគេដកមកវិញឃើញស្វាត់ជ្រាប ខ្ញុំដើរទៅមើលឃើញសាកសពក្នុងអណ្តូង ខ្លះកប់ដីមិនជិន ឃើញធ្មេញស្ញេញៗ ខ្ញុំបានដកធ្មេញ (ធ្មេញដាក់) ពីខ្មោច២សម្រាប់មកទុក។

ខ្សែធាងត្នោតនោះ ខ្ញុំបានត្រឹមតែបិតជាខ្សែបន្ទុះៗប៉ុណ្ណោះ រួចក៏ប្រធានភូមិមកយកទៅមិនដឹងយកទៅទីណា។ មាន៧៦រណ្តៅ រណ្តៅធំជាងគេមានទំហំជាង១០ម៉ែត្រ ដាក់សាកសព៧០គ្រួសារ, ចំនែករណ្តៅតូចមានទំហំប្រហែលទទឹង២ បណ្តោយ៣ ជំរៅ២ម៉ែត្រ។ សាកសពដាក់តំរៀបផ្ទុយក្បាលគ្នារណ្តៅទាំងនោះដឹកនៅខាងជើងវត្តប្រហែល២០០-៣០០ម៉ែត្រ។ កន្លែងនោះហៅថា ត្រពាំងអណ្តូង និងត្រពាំងស្នុង។ ចំនួនសាកសពប្រហែលរាប់ម៉ឺននាក់។ មួយរណ្តៅៗមានសាកសពតិចបំផុត៣០នាក់។ សម្លាប់ភាគច្រើននៅឆ្នាំ១៩៧៥។ សម្លាប់តែរយៈពេល៩ថ្ងៃ ច្រើនដឹកមកពីភ្នំពេញភាគច្រើន, ឈើទាលជ្រុំ.......។ ឡានចេញទៅវិញ ឃើញសុទ្ធតែខោអាវ គ្មានមនុស្ស។ របស់របរជាប់មកជាមួយខ្លួនត្រូវពួកវា(ខ្មែរក្រហម)សំរាតយកអស់នៅសល់តែខ្លួន។ អ្នកត្រូវសម្លាប់ដែលដឹកយកមកគឺដាក់នៅក្នុងវត្តសិនទើបបញ្ជូនទៅកាន់ទីតាំងសម្លាប់ស្ថិតនៅទិសខាងជើង។ គណៈស្រុកឈ្មោះ ទូច (ស្លាប់)។ ខ្ញុំមានគ្រួសារស្លាប់ក្នុងជំនាន់ប៉ុលពតអស់១៥នាក់ នៅវត្តកោះខ្លះ។ ឆ្អឹងបានគាស់យកមកដាក់នៅវត្តទ្រព្យគរខ្លះដោយសារកាលនោះមានប្រជាជននាំគ្នាទៅគាស់រកមាស រួចក៏បញ្ជូនឆ្អឹងមកដាក់នៅចេតីយ៍ក្នុងវត្តទ្រព្យគរ

តាមចៅហ្វាយស្រុកប្រាប់នៅឆ្នាំ១៩៨០ ។ ខ្ញុំនៅចាំថាខ្សែដែលខ្ញុំធ្លាប់បិត ហើយត្រូវប្រធានភូមិយកទៅនោះឃើញនៅជាប់ចំណងដៃ-ជើងសាកសពទៅវិញ ។

## សេចក្ដីសន្និដ្ឋាន

ក្នុងរយៈពេល៣ថ្ងៃនៃការចុះទៅស្រាវជ្រាវដល់ទីតាំងចំនួនពីរគឺ មន្ទីរសន្តិសុខនិងកន្លែងសម្លាប់វត្តសុភី ហៅ កកោះ, មួយទៀតគឺ ខាងជើងបរិវេណវត្តទ្រព្យគរប្រហែល៣០០ម៉ែត្រ ។ យោងតាមការសិក្សាស្រាវជ្រាវរបស់ក្រុមដែនទីទៅលើទីតាំងនៅវត្តសុភី ហៅ កកោះ, យើងបានឲ្យដឹងយ៉ាងច្បាស់ថា ពិតជាមានការជីងព្រូផ្សេងៗពីគ្នាពីមួយឆ្នាំ ទៅមួយឆ្នាំ ជាក់ស្ដែងៈ

-នៅឆ្នាំ១៩៧៣-៧៤, នៅក្នុងបរិវេណព្រះវិហារវត្តកកោះមានអ្នកទោសតិចតួចទេ ប្រមាណតែ៥០-៦០នាក់ប៉ុណ្ណោះ ។ ចំណែកការធ្វើទារុណកម្មនិងការសម្លាប់វិញ ក៏នៅមានកំរិតតិចបំផុតដែរ ។ សំដីរបស់លោកតា សួរ ញ៉ូ និយាយដូច្នេះថា មានអ្នកទោសចំនួនតែពីរខ្សែគត់ ហើយមួយខ្សែៗមានពី២០-៣០ នាក់ ព្រមទាំងមានការវៃធ្វើបាបជាបណ្ដើរៗហើយ រហូតដល់មានការវះពោះមនុស្សទាំងរស់ទៀត ។

-នៅឆ្នាំ១៩៧៥, យោងតាមសំដីរបស់លោក ប៊ុន ហ៊ីង ជាអនិកជនខ្មែររស់នៅសហរដ្ឋអាមេរិកថា មានការសម្លាប់ច្រើនតែប្រជាជនដែលជម្លៀសចេញពីទីក្រុងភ្នំពេញ ដែលកាលនោះមានឈ្មោះ អ៊ុយ អនុប្រធានភូមិភាគនិរតីជាអ្នកសម្លាប់ច្រើនជាងគេ ។ លោក ហ៊ីង បន្តថានៅវត្តកកោះមានសម្លាប់រហូតដល់៦-៧ម៉ឺននាក់ បូករួមទាំងក្មេង-ចាស់-ប្រុស-ស្រី ។ ទីតាំងសម្លាប់ស្ថិតនៅក្នុងស្រះទឹកខាងជើង, ខាងកើត, និងខាងត្បូង ។

-ពីឆ្នាំ១៩៧៦-៧៨, មានការធ្វើទារុណកម្ម និងសម្លាប់ច្រើន ។ មានការសម្លាប់ជារៀងរាល់ថ្ងៃដោយក្នុងមួយថ្ងៃៗមានមនុស្សស្លាប់ពី៥០-១០០នាក់ ។ ពេលសម្លាប់មានបញ្ជីមួយមកបើកមើល និងជ្រើសរើសយកអ្នកដែលត្រូវសម្លាប់ ។ ឈ្មោះអ្នកត្រូវស្លាប់ត្រូវបានគណៈស្រុកគូសខ្វែងជើងក្អែកដោយប៊ិចក្រហម ។ ជនរងគ្រោះចំនួនប្រហែល២០០០០នាក់ បានស្លាប់ក្នុងអំឡុងឆ្នាំនេះ ។

-ចាប់ពីថ្ងៃរំដោះរហូតដល់បច្ចុប្បន្ន, ទីវត្តនេះនៅតែបានបន្សល់នូវស្លាកស្នាមជាក់ស្ដែងដូចជា ខ្មោះស្នាមចោះទំលុះជញ្ជាំងព្រះវិហារ...។ មានអដ្ឋិធាតុប្រហែលនឹងមួយភាគប្រាំនៃអដ្ឋិធាតុទាំងអស់ដែលនៅក្នុងដីត្រូវបានយកមកតំកល់ទុកនៅកន្លែងមួយដែលស្ថិតនៅខាងកើតឈៀងខាងត្បូងព្រះវិហារវត្តកកោះ ។ ព្រះសង្ឃព្រះនាម កែវ កុសល បានមានពុទ្ធដីការថា ឆ្អឹងដែលយកមកតំកល់នេះ ភាគច្រើនជាឆ្អឹងលលាដ៍

ក្បាល ហើយស្រះខាងមុខព្រះវិហារសព្វថ្ងៃនេះ មិនអាចប្រើប្រាស់ទឹកបានទេកាលពីមុនឆ្នាំ១៩៩០ព្រោះខាងក្នុងស្រះមានសុទ្ធតែខ្មោចមនុស្សអណ្តែតលើទឹក ។ ព្រះតេជគុណបានធ្វើការប៉ាន់ស្មានថាមានចំនួនសាកសពរួមទាំងអស់ប្រមាណរាប់ម៉ឺន-រាប់សែននាក់ ។

ចំណែកឯនៅវត្តទ្រព្យគរដែលស្ថិតនៅឃុំត្រពាំងសាប ស្រុកបាទីវិញ ក៏មានការសម្លាប់មនុស្សជាច្រើនដែរនៅប៉ែកខាងជើងព្រះវិហារចំងាយប្រហែល៣០០ម៉ែត្រ ។ សំដីរបស់លោកតា ប្រាក់ អឹម និយាយថា មាន៧៦រណ្តៅ ក្នុងនោះមានរណ្តៅធំចំនួន២ ហើយអាចដាក់ជនរងគ្រោះបានជាង៧០គ្រួសារ និងក្រៅពីនោះជារណ្តៅតូចៗ ។ សាកសពរួមមានប្រមាណ៣-៨នាក់, នេះជាសំដីរបស់លោកប៊ុន ហ៊ីង ។ ទីតាំងនេះចាប់ផ្តើមសម្លាប់មនុស្សតាំងពីឆ្នាំ១៩៧៥ ។ ប្រភេទប្រជាជនច្រើនយកមកពីឈើទាលជ្រុំ ឃុំក្រាំងលាវ ស្រុកបាទី និង ប្រជាជនដែលបានជម្លៀសចេញពីទីក្រុងភ្នំពេញ ។ ទីតាំងវត្តនេះ មិនមែនជាមន្ទីរសន្តិសុខរបស់ខ្មែរក្រហមទេ, យោងតាមសំដីរបស់លោកតា ប្រាក់ អឹមថាវត្តនេះគ្រាន់តែជាកន្លែងស្តុបមនុស្សបណ្តោះអាសន្នប៉ុណ្ណោះ ។ ឯមនុស្សដែលត្រូវសម្លាប់ ហើយសម្លាប់មិនទាន់នៅវត្តទ្រព្យគរត្រូវបានពួកខ្មែរក្រហមបញ្ជូនមកកាន់វត្តអូរពង្ស៍ ដើម្បីត្រៀមសម្លាប់ចោល ។ ប៉ុន្តែមិនទាន់បានសម្លាប់ទេ ព្រោះត្រូវបែកកាលពីឆ្នាំ១៩៧៩ ។ ទោះជាយ៉ាងនេះក្តី ក៏នៅមានជនរងគ្រោះមួយចំនួនបានស្លាប់បាត់បង់ជីវិតដោយសារជម្ងឺជាច្រើននាក់ដែរ ។